ឧបសៅសង្ហា




# ប្រជុំអត្ថបទ ឆ្នាំ ២០១៧

## លេខ ទី៣




កសិករខ្មែរនៅសតវត្ស ទី១៩

## ឈុត នៃ ការពិភាក្សានយោបាយ

### មាតិការឿង


សុច្ឆន្ទៈ ឬ ទុច្ឆន្ទៈ ? ........................................................ 2

សតិសម្បជញ្ញៈ និង អធ្យាប័នម៉ឺងម៉ាត់........... 5

ឆ្នាំងដែក និង ឆ្នាំងដី .............................................. 8

# សុច្ចន្ទៈ ឬ ទុច្ចន្ទៈ ?

១៥ មីនា ឆ្នាំ ២០១៧

សុប្រភាព[1] របស់ លោក ហ៊ុន សែន នៅ ក្នុង ជីវភាព នយោបាយ វា ក្លាយ ជា ច្បាប់ជាតិ សំរាប់ អំណាច នីតិប្រតិបត្តិ, នីតិបញ្ញត្តិ និង តុលាការ យក មក អនុវត្ត ជា ដាច់ខាត ព្រោះ ស្រុកខ្មែរ វា គ្មាន នីតិរដ្ឋ និង ប្រជាពលរដ្ឋធិបតេយ្យ តែ នៅ ស្រុកខ្មែរ មាន ការបោះឆ្នោត គ្រប់ ថ្នាក់ ជា និច្ច ស្របតាម រដ្ឋធម្មនុញ្ញ ដែល នាំ អោយ សុប្រភាព របស់ លោក ហ៊ុន សែន មាន លក្ខណៈ ស្រប ច្បាប់ ព្រោះ គណបក្សនយោបាយ ចូលប្រគួត តែងតែ ទទួលស្គាល់ ជា និច្ច នៅ ទី បំផុត នូវ លទ្ធផល នៃ ការបោះឆ្នោត ទោះ បី វា ជា លទ្ធផល គេចកែ (déformer la vérité) ក៏ដោយ។ តើ រហូតតទៅ គេ អាច ទុក ការបោះឆ្នោត វា គ្រាន់តែ ជា មធ្យោបាយ សំរាប់ លោក ហ៊ុន សែន រក្សា សុប្រភាព របស់គាត់ តែ ប៉ុណ្ណោះឬ ?

ចម្លើយ នឹង សំនួរ នេះ វា មាន ការពាក់ព័ន្ធ នឹង សេចក្តីថ្លែងការណ៍ របស់ លោក កឹម សុខា គឺថា គាត់ មាន ជំនឿទាំងស្រុង ថា គណបក្សសង្គ្រោះជាតិ ដឹកនាំ ដោយគាត់ នៅ ពេល បោះឆ្នោត ខាងមុខ នេះ ទាំង ថ្នាក់ ឃុំ-សង្កាត់

[1] តេជៈអំណាច; អំណាចខ្លាំង

និង ជាតិ គឺ ពិត ជា មាន ជ័យជំនះ។ សំដី លោក កឹម សុខា ប្រកប ដោយ ឧស្សាហភាព (diligence) នេះ នាំ អោយ មាន សំនួរ សួរ ថា តើ ជា សុច្ឆន្ទៈ ឬ ទុច្ឆន្ទៈ របស់គាត់ ដោយរកហេតុ អំពី ការប្រាស័យទាក់ទង ពិសេស រវាង គាត់ នឹង លោក ហ៊ុន សែន ?

## អ្វី ខ្លះ ដែល ជា មូលគំនិត របស់ លោក កឹម សុខា និង ហ៊ុន សែន ?

**ការបោះឆ្នោត** ទោះបី នៅ ក្នុង លក្ខណៈ បែបណា ក៏ដោយ ជា មូលគំនិត ទី១ ព្រោះ អ្នក ទាំងពីរ មាន ប្រយោជន៍ រួម គឺ ការរក្សា បុព្វសិទ្ធិ រៀងៗខ្លួន គឺថា លោក ហ៊ុន សែន រក្សា អំណាច រីឯ លោក កឹម សុខា វិញ នឹងបាន ទទួល អំណោយ ពី អំណាច។ លទ្ធផល នៃ ការបោះឆ្នោត វា គ្មាន តម្លៃ សំរាប់ លោក ទាំងពីរ នោះឡើយ ព្រោះ ទោះបី គណបក្សសង្គ្រោះជាតិ ឈ្នះ ឆ្នោត ដូច នៅ ឆ្នាំ ២០១៣ ក៏ អ្នក ដឹកនាំ គណបក្ស ហ្នឹង នឹងទទួល យក ការប្រកាស លទ្ធផល របស់ គ.ជ.ប. តាម ការចង់បាន របស់លោក ហ៊ុន សែន ជា បានការ ព្រោះ លោក ហ៊ុន សែន គាត់ ប្រកាស រួចហើយ ថា គាត់ មិន ព្រមចាញ់ ជា ដាច់ខាត បើ ចាញ់ គឺ មាន សង្គ្រាម។

**សត្រូវ នយោបាយរួម** ជា មូលគំនិត ទី២ ព្រោះ លោក ហ៊ុន សែន គាត់ ទុក លោក សម រង្ស៊ី ជា សត្រូវនយោបាយ

របស់គាត់ ក៏ដូចជាផ្ទុយទៅវិញ (vice-versa) ប៉ុន្តែ គាត់ ទុក លោក គឹម សុខា ជា ដៃគូ របស់គាត់ ដូច ពាក្យទំនឹម ទំនៀង ថា « សត្រូវ របស់ មិត្តខ្ញុំ ជា សត្រូវ របស់ខ្ញុំ »។ ចង់ ឬ មិនចង់ លោក គឹម សុខា គាត់ ត្រូវតែ គោរព គោល ការណ៏ នេះ ព្រោះ សេចក្តីសុខ របស់គាត់ វា ជា អំណោយ របស់ លោក ហ៊ុន សែន ផ្តល់ អោយ គាត់ ដូច លោក ហ៊ុន សែន និយាយប្រាប់ គាត់ តាម ទូរស័ព្ទ ថា « បើ ខ្ញុំ មិន បញ្ជា អោយ គេ ចាប់ ខា ឯង វា គ្មាន នរណា មួយ គេ ហ៊ាន ចាប់ ខា ឯង ទេ »។

**មែករួម** ក្នុង ចំណោម មែក ដទៃ ទៀត នៃ ដើមឈើ សង្គមខ្មែរ គឺថា លោក ទាំងពីរ គាត់ ទុំ លើ មែក ដែល យួន គេ មាន បញ្ញាអាច ផ្សាំ អោយ ចាប់ ឫស នៅ ក្នុង សង្គមខ្មែរ ដើម្បី សំរាប់ ប្រជាជនយួន ទុក ជា ជំរកថ្មី សំ រាប់ ប្រជាជាតិគេ។ មែករួម នេះហើយ ជា មូលដ្ឋាន នៃ ជីវិតរួម របស់ លោក ទាំងពីរ; ម្នាក់ដើរតួ ជា អ្នក រក្សា មោនភាព (tranquillité) ដល់ សហគមន៏យួន នៅ ស្រុក ខ្មែរ ដែល លោក ហ៊ុន សែន គាត់ អោយ ឈ្មោះ ថា សន្តិ ភាព; ម្នាក់ទៀត ដើរតួ ជា អ្នក សង្គ្រោះ របបផ្តាច់ការ ដែល លោក គឹម សុខា គាត់ យក ការបោះឆ្នោត ជា ឧបាយបញ្ឆោត រាស្ត្រ ដូចគ្នា នឹង លោក ហ៊ុន សែន ព្រោះ គាត់ ទុក វា ជា ជម្រើសទោល (choix unique) សំរាប់ខ្មែរ។

មូលគំនិត ដែលបាន រៀបរាប់ ខាង លើ នេះ នាំ អោយ យើង ចោទ សួរ ជា សំនួរ ថា គ្រប់ សកម្មភាព របស់ លោក កឹម សុខា សព្វថ្ងៃ នេះ តើ ជា អំពើ មាន សុច្ចន្ទៈ ឬ ជា អំពើ ទុច្ចន្ទៈ សំរាប់ ប្រជាជាតិខ្មែរ ?

**ពាក្យច្រើនភូត ចាញ់អាត្មា។**

## សតិសម្បជញ្ញៈ និង អធ្យាប័នម៉ឺងម៉ាត់

៨ មីនា ២០១៧

អធ្យាប័នម៉ឺងម៉ាត់ (consigne) របស់ លោក ហ៊ុន សែន ចំពោះទៅ លោក កឹម សុខា តើ វា អាច ចោទ ជា សំនួរ នៅ ក្នុង សតិសម្បជញ្ញៈ របស់ លោក កឹម សុខា ដែរឬទេ ?

រឿង ហ្នឹះ វា អាស្រ័យ ទៅ លើ ការបែងចែក ច្បាស់លាស់ នៃ ប្រយោជន៍ជាតិ និង ប្រយោជន៍ផ្ទាល់ខ្លួន របស់ លោក កឹម សុខា។ បើ លោក កឹម សុខា គាត់ យក ប្រយោជន៍ ជាតិ ជា គោលការណ៍ សំខាន់ ច្បាស់ ជា សតិសម្បជញ្ញៈ របស់គាត់ ជា អ្នក សង្គ្រោះជាតិ វា នឹង បំភ្លឺ គតិ (voie morale) របស់គាត់។ តែ បើ លោក កឹម សុខា គាត់ ទុក ប្រយោជន៍ផ្ទាល់ខ្លួន ជា ត្រីមុខ ច្បាស់ ជា អធ្យាប័នម៉ឺង

ម៉ាត់ របស់ លោក ហ៊ុន សែន វា ជា ច្បាប់ សំរាប់ គាត់ យក មក អនុវត្ត ជា ដាច់ខាត។

តែ យើង ដឹង ថា នៅ ស្រុកខ្មែរ សព្វថ្ងៃ សីមា រវាង ប្រយោជន៍ជាតិ និង ប្រយោជន៍ផ្ទាល់ខ្លួន វា គ្មាន មាន ខ្សែ គូស ពិស្តារនោះឡើយ ព្រោះ នៅ ស្រុកខ្មែរ វា គ្មាន នីតិរដ្ឋ ដែល នាំ អោយ អ្នកខ្លាំង ជា ម្ចាស់ នៃ ច្បាប់ ឯចំណែក អ្នក ខ្សោយ ជា អ្នក ទទួលរង គ្រោះ នឹង ការរំលោភ របស់ អ្នក ខ្លាំង ហើយ ស្រុកខ្មែរ ជា ប្រទេសក្រ ដូច្នេះ សេចក្តីត្រូវការ នៃ ជីវសាស្ត្រ (besoin biologique) របស់ បុគ្គល ម្នាក់ៗ វា ជា សេចក្តីត្រូវការ ទី១ សំរាប់ ជីវភាព រស់នៅ របស់ ប្រជាពលរដ្ឋ ដែល វា នាំ អោយ មនុស្ស ម្នាក់ៗ មាន ចរិត គិត តែខ្លួនឯង ដូច ខ្មែរយើង ទម្លាប់ និយាយថា « គិតជាតិ ពេក ប្រយ័ត្ន ពោះដាច់ បាយ »។ អាស្រ័យហេតុនេះ សេចក្តីត្រូវការ កិត្តិយស វា មិន អាច ឈ្នះ នឹង គំលាន របស់ ក្រពះ បាន នោះឡើយ។ ដូច មាន នៅ ក្នុង យុទ្ធសាស្ត្រ នយោបាយ នៃ ពួក កុម្មុយនិស្ត ថា « បើ ចង់ អោយ រាស្ត្រ ខ្លាច គឺ ត្រូវ ធ្វើ នយោបាយ អោយ រាស្ត្រ ឃ្លានហូប គឺ ថា បង្អត់ បាយ រាស្ត្រ »។

ថ្មីៗនេះ លោក កឹម សុខា គាត់ ថ្លែង ថា ខ្មែរយើង ត្រូវ ចែកគ្នា រស់ កុំ ដណ្តើមគ្នា រស់។ សំដី នេះ ជា សារ ផ្ញើរ ចំពោះ ទៅ លោក ហ៊ុន សែន ច្រើនជាង ចំពោះ ទៅ ប្រជា

ពលរដ្ឋខ្មែរ នោះ បី សារ ឈ្មោះ វា មាន លក្ខណៈ ជា អនុសាសន៏ ប្រហែល សំរាប់ លុបបំបាត់ នូវ អត្ថទត្ថភាព មាន នៅ ក្នុង សង្គមខ្មែរ សព្វថ្ងៃ ក៏ដោយ ព្រោះ ការសូមរស់ និង សូមសុខ ពី លោក ហ៊ុន សែន វា ជា ផ្លូវ ដើរ មិន អាច វៀរចាកបាន របស់ អ្នកនយោបាយ គ្រប់ គោលនិយម, ទាំង សព សម្តេច សីហនុ, តាំង ពី ឆ្នាំ ១៩៩១ មកម្លេះ។ ដូច្នេះ ការណ៏ អ្វី ដែល មាន កើតឡើង សព្វថ្ងៃ វា ជា ការ បន្ត មាន ហេតុផល របស់វា ច្បាស់លាស់ គឺ ប្រតិបាទន៍ នៃ ចំណង់ របស់ លោក ហ៊ុន សែន តែ ប៉ុណ្ណោះ។ មិន ដូច អ្នក ខ្លះ យល់ឃើញ ថា លោក ហ៊ុន សែន អស់ ក្បួន បែរ ជា ប្រើ ឧបាយកល ថោកទាប; យើង សួរ ថា តើ នៅ ពេល ណា មួយ ដែល លោក ហ៊ុន សែន គាត់ ធ្លាប់ បានប្រើ មធ្យោបាយ សុច្ចរិត ? ព្រោះ មក ដល់ ថ្ងៃនេះ ឧបាយកល ទុច្ចរិត របស់ លោក ហ៊ុន សែន វា តែងតែ អោយ គាត់ មាន ជ័យជំនះ ជា និច្ច មិន តែប៉ុណ្ណោះ ភាពទុច្ចរិត នោះ វា តែងតែ លោក សម រង្ស៊ី ក្តី លោក កឹម សុខា ក្តី ទទួល ស្គាល់ ជា ផ្លូវការ តាម ការចូលរួម ធ្វើ សហការ នៅ ក្នុង រដ្ឋសភា បដិរដ្ឋធម្មនុញ្ញ និង នៅ ក្នុង ក្របខណ្ឌ វប្បធម៏ សន្ទនា។ ដូច្នេះ តាម គន្លង នេះ វា ត្រូវតែ លោក កឹម សុខា គាត់ យក ជា ឧទ្ទាត៏ា (chemin du mal) សំរាប់ បន្ត ដើរ ក្នុង នាម គាត់ ជា ប្រមុខ ថ្មី នៃ គណបក្សសង្រ្គោះជាតិ។ ក្បីណនោះ ពាក្យស្លោក « ដូរ ឬ មិនដូរ » វា ច្បាស់ ជា

លោក កឹម សុខា គាត់ មិន យក មក ប្រើ ទៀត នោះ ឡើយ ព្រោះ ប្រហែល ជា គាត់ ខ្លាច ខុស អធ្យាប្រ័នម៉ឹង ម៉ាត់ របស់ លោក ហ៊ុន សែន។

សាធុ ! សាធុ ! សូម អោយ ខ្មែរ ចេះ ចែកគ្នា រស់ ដូច លោក ហ៊ុន សែន នឹងចែកអោយ លោក កឹម សុខា រស់នោះឯង។

**អ្នកមានប្រាជ្ញាតែងតែកែអាត្មាអោយជាតិសុខចម្រើន៕**

## ស្នាំងដែក និង ស្នាំងដី

១៧ កុម្ភៈ ២០១៧

លោក ហ៊ុន សែន ប្ដឹង លោក កឹម សុខ គ្មាន ហេតុផល ទាមទារ ជំងឿចិត្ត រាប់សែន ដុល្លារ (US) នាំបង្ហាញ អោយឃើញ ថា ការប្ដឹង ហ្នេះ វា មាន រូបភាព ជា ការបំពាន ប្រើ អំណាច ជិះជាន់ ជនសាមញ្ញ ដែល គ្មានអ្វីសោះ សំរាប់ ការពារ សិទ្ធិខ្លួន ជា ពលរដ្ឋ។ នៅចំពោះមុខ អយុត្តិធម៌ បែប ហ្នេះ វា គ្មានឃើញមាន ប្រតិកម្ម ជាក់ស្ដែង ពី សំណាក់ មហាជន ជា ពិសេស យុវជន និង បញ្ញវន្ត ដែល ស្រឡាញ់ យុត្តិធម៌ និង សីលធម៌។ តុណ្ហីភាព (silence) បែបនេះ ដែល នាំអោយ លោក ហ៊ុន សែន ឥត រញ៉េរា បន្ត ប្រើ អំណាចផ្ដាច់ការ ដើម្បី បំផ្លាញអោយសាបសូន្យ ដល់ សេរីភាព បញ្ចេញមតិ ដែល ជា សេរីភាព សំខាន់ ការពារ

ដោយ ច្បាប់រដ្ឋធម្មនុញ្ញ។ ករណី ហ្នេះ ខ្មែរយើង ហាក់បីដូចជា មិនយក មរណភាព លោក កែម ឡី មកទុក ជា មេរៀន នោះឡើយ។ កង្វះ នៃ ការប្រុងប្រយ័ត្ន ហ្នេះហើយ ដែល វា នឹងអាចនាំ អោយមាន អំពើផ្ដួន ជាថ្មី ដល់ លោក គឹម សុខ។

លោក ហ៊ុន សែន គាត់ ជា ឆ្នាំងដែក ទង្គិច នឹង លោក គឹម សុខ ជា ឆ្នាំងដី វា ច្បាស់ ជា ឆ្នាំងដី បែក ជា ពុំខាន តែ បើ ខ្មែរយើង ធ្វើ ជា រនាំង ការពារ ឆ្នាំងដី វា នឹងអាច ចៀសបាន នូវ ការទង្គិច នោះ។ ការពារ លោក គឹម សុខ មិនមែន ជា ការការពារ បុគ្គល នោះឡើយ វា ជា ការ ការពារ គោលការណ៏ ជា គោល នៃ សិទ្ធិ របស់ ពលរដ្ឋ ដូច្នេះ វា ជា ការការពារ សិទ្ធិ របស់ ជនខ្មែរ ម្នាក់ៗ ដែល មាន ច្បាប់ ជា អំណាច។ បើ ខ្មែរយើង នាំគ្នា បែរខ្នង ដាក់ លោក គឹម សុខ គឺ ខ្មែរយើង កំពុង នាំគ្នារស់ សំរាប់ តែ ជីវិតអាត្មា រៀងខ្លួនៗ ហើយ ចាគប័ត្រ (résigner) នៅ ចំពោះ អំពើ អយុត្តិធម៌ និង ការគាបត្បៀត គ្រប់បែប យ៉ាង ពី សំណាក់ អំណាចផ្តាច់ការ៕